KH008

ÆON
ធនាគារឯកទេស

# សៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់
# អ៊ីអនកាត




ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
ÆON SPECIALIZED BANK (CAMBODIA) PLC.



## ជូនចំពោះអតិថិជនជាទីគោរព
## សូមស្វាគមន៍ម្ចាស់អ៊ីអនកាត

តំណាងឲ្យ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី យើងខ្ញុំមានសេចក្តីរីករាយ ដែលលោកអ្នកជឿទុកចិត្តលើសេវាកម្មរបស់យើងខ្ញុំ និងយល់ព្រមធ្វើជាម្ចាស់អ៊ីអនកាត។

អ៊ីអនកាត ត្រូវបានបង្កើតឡើងជាសេវាឥណទានសុទ្ធសាធ ដោយផ្តល់អត្ថប្រយោជន៍ពិសេសជាច្រើនដល់អតិថិជនដូចជា មិនគិតថ្លៃសេវាប្រចាំឆ្នាំ (អ៊ីអនកាតពណ៌ស្វាយ) ការសន្សំពិន្ទុបុព្វសិទ្ធិពាណិជ្ជករ និងកម្មវិធី AEON Thanks Day។

អ៊ីអនកាត ជាសេវាកម្មកាតដែលឆ្លើយតបទៅតាមតម្រូវការរបស់អតិថិជន ដែលរីករាយជាមួយការប្រើប្រាស់ប្រចាំថ្ងៃ ដោយសារលោកអ្នកអាចប្រើប្រាស់កាតនៅតាមហាងជាង 46លានកន្លែង និងម៉ាស៊ីនATM ចំនួនជាង 2.6លាននៅទូទាំងពិភពលោក។ អ៊ីអនកាត ត្រូវបានរចនាឡើងដើម្បីផ្តល់ភាពងាយស្រួលជូនអតិថិជន ក្នុងការទិញទំនិញតាមហាង ឬតាមអនឡាញ និងការដកប្រាក់ជាមុន។

យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងរីករាយជាមួយអត្ថប្រយោជន៍ពិសេសរបស់អ៊ីអនកាត ហើយយើងខ្ញុំសូមសន្យាថា នឹងពង្រីកសេវាកម្មរបស់យើង ព្រមទាំងផ្តល់សេវាកម្មស្តង់ដារអន្តរជាតិ ដែលបំពេញតម្រូវការរបស់អតិថិជនក្នុងកម្រិតអតិបរមា។

ដោយក្តីគោរព
**ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី**

# អត្ថប្រយោជន៍នៃអ៊ីអនកាត



## ការទិញទំនិញ និងសេវាកម្ម



ឆូតកាតលើ
ម៉ាស៊ីនឆូតកាត POS



ផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់
និងចុះហត្ថលេខាលើវិក្កយបត្រ

ក្នុងពេលបច្ចុប្បន្ននេះ  អ៊ីអនកាតរបស់លោកអ្នកត្រូវបានទទួលស្គាល់ដោយពាណិជ្ជករជាង 46លានកន្លែងនៅទូទាំងពិភពលោកនៅគ្រប់ទីកន្លែងដែលមានស្លាកសញ្ញាVISA។

ពាណិជ្ជករនឹងស្នើសុំឲ្យលោកអ្នកពិនិត្យមើលចំនួនទឹកប្រាក់ប្រតិបត្តិការរបស់លោកអ្នក និងស្នើសុំឲ្យលោកអ្នកចុះហត្ថលេខាលើវិក្កយបត្រលក់ ដែលមានព័ត៌មានលម្អិតពីអ៊ីអនកាតរបស់លោកអ្នក  និងចំនួនទឹកប្រាក់នៃប្រតិបត្តិការ  ដែលត្រូវទូទាត់នៅក្នុងរបាយការណ៍វិក្កយបត្ររបស់លោកអ្នក។

សូមពិនិត្យមើលចំនួនទឹកប្រាក់របស់លោកអ្នក ដែលបានរៀបរាប់នៅលើវិក្កយបត្រលក់ មុនពេលចុះហត្ថលេខាលើវិក្កយបត្រនោះ។



# ការដកប្រាក់ជាមុន



- បញ្ចូលកាតក្នុងម៉ាស៊ីន ATM



- បញ្ចូលលេខកូដសម្ងាត់
- ជ្រើសយកការដកសាច់ប្រាក់
- ជ្រើសរើស ឬវាយបញ្ចូលនូវចំនួនទឹកប្រាក់ដែលត្រូវការ



- ដកកាតចេញ



- យកសាច់ប្រាក់

លោកអ្នកអាចដកសាច់ប្រាក់ដោយប្រើអ៊ីអនកាត ជាមួយនឹងលេខកូដសម្ងាត់ (PIN) របស់លោកអ្នក។ ការដកប្រាក់ជាមុនអាចធ្វើនៅតាមម៉ាស៊ីន ATM ណាមួយក៏បាន ដែលមានបង្ហាញស្លាកសញ្ញា VISA ឬ PLUS ។

| ម៉ាក | VISA |
|---|---|
| ស្លាកសញ្ញា | VISA PLUS |
| កម្ពុជា | ជាង 1.520 ម៉ាស៊ីន ATM |
| ពិភពលោក | ជាង 2,6 លាន ម៉ាស៊ីន ATM |



## អត្ថប្រយោជន៍របស់អ៊ីអនកាត

លោកអ្នកនឹងឃើញពីអត្ថប្រយោជន៍ពិសេសផ្តាច់មុខ ដែលនាំមកជូនលោកអ្នកដោយ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។ លោកអ្នកនឹងមានសេរីភាព ក្នុងការរស់នៅតាមរបៀបដែលលោកអ្នកចង់បាន។

AEON ធនាគារឯកទេស AEON Gold Card ALLIANCE PARTNER • សមាជិកអ៊ីអនកាតពណ៌មាស •

AEON ធនាគារឯកទេស ALLIANCE PARTNER • សមាជិកដៃគូសហការ •

## ដៃគូសហការរបស់អ៊ីអនកាត

រីករាយជាមួយនឹងការបញ្ចុះតម្លៃជាច្រើននៅតាមហាងទំនើបៗ ដែលជាដៃគូសហការដោយផ្តល់ជូននូវការបញ្ចុះតម្លៃរហូតដល់ទៅ 50%។

# អាហារ និង ភេសជ្ជៈ

| | | | | |
|---|---|---|---|---|
| 30% | Up to 25% | 20% | 20% | 20% |
| 20% | 20% | 15% | 15% | 10% |
| 10% | 10% | 10% | 10% | 10% |
| 10% | 10% | 10% | 10% | 10% |
| 10% | 10% | 10% | 10% | 10% |
| 10% | 10% | 10% | 10% | 10% |

| | | | | |
|---|---|---|---|---|
| 10% | 10% | 10% | 10% | 10% |
| 10% | 5% | 5% | 5% | 5% |
| 5% | 5% | 5% off | 5% | 5% |
| 5% | 5% | 5% | 5% | 5% |
| 5% | 5% | 5% | 5% | 5% |

## ម៉ូត និង សម្លៀកបំពាក់

| | | | | |
|---|---|---|---|---|
| Up to 50% | 35% | 33% | 30% | 30% |
| 20% | 20% | 20% | 20% | 10% |
| 10% | Up to 10% | 10% | 10% | 15% |
| 10% | 10% | 10% | 10% | 10% |

| | | | | |
|---|---|---|---|---|
| 10% | 10% | 10% | 10% | 10% BELEZA |
| 10% Baleno | 8% DE KIDS | 5% ZONO | 5% | 5% U.KNOW |
| 5% | 5% | 5% Superdry | 5% Reebok | 5% |
| 5% Pedro | 5% PARFUMERIE | 5% OVS | 5% | 5% MIZON |
| 5% | 5% | 5% FILA | 5% | 5% |
| 5% Calvin Klein | 5% BONIA | 5% A\|X ARMANI EXCHANGE | 5% adidas GOLF | 5% adidas |

## ដំណើរកម្សាន្ត និង ការកម្សាន្ត

| | | | | |
|---|---|---|---|---|
| 50% | 30% | 20% | 20% | 20% |
| 20% | 15% | 10% | 10% | 10% |
| 10% | 10% | 10% | 10% BOTUM | 5% |
| 5% MUSIC | 5% | 5% Hi Store | 5% ECO | 5% DAILY MART |

# សុខុមាលភាព និង ផ្សេងៗ

| | | | | |
|---|---|---|---|---|
| Up to 50% | Up to 50% | Up to 30% | 30% | 30% |
| 20% | 20% | Up to 20% | 15% | Up to 15% |
| Up to 15% | 15% | 15% | Up to 10% | 10% |
| 10% | 10% | 10% | Up to 10% | 10% |
| 10% | 10% | 10% | 10% | 10% |
| 10% | 10% | 10% | 10% | 10% |
| 10% | 10% | 5% | 5% | 5% |
| 5% | 5% | 5% | 5% | 5% |
| 5% | 5% | 5% | 5% | 5% |



## កម្មវិធី AEON Thanks Day




រាល់ម្ចាស់អ៊ីអនកាតទាំងអស់ អាចរីករាយជាមួយការបញ្ចុះតម្លៃពិសេស 5% នៅផ្សារទំនើបអ៊ីអន ភ្នំពេញ ផ្សារទំនើបអ៊ីអន សែនសុខ ស៊ីធី និង AEON MaxValu Express នៅរៀងរាល់ថ្ងៃទី20 និងទី30 នៃខែនីមួយៗ។

**លក្ខខណ្ឌ៖**

ត្រូវប្រើប្រាស់អ៊ីអនកាត ដើម្បីធ្វើការទូទាត់វិក្កយបត្រថ្លៃទំនិញ

- លើកលែងចំពោះផលិតផលមួយចំនួន
- លើកលែងចំពោះផលិតផល ដែលមានស្លាកសញ្ញាបញ្ចុះតម្លៃ
- លើកលែងចំពោះកម្មវិធីប្រម៉ូសិនរបស់កាតផ្សេងទៀត

## កម្មវិធី Happy Plus Point

រាល់ការចំណាយ 2ដុល្លារ លោកអ្នកនឹងទទួលបាន 1ពិន្ទុ ហើយ 500ពិន្ទុ លោកអ្នកអាចប្តូរយកជាប័ណ្ណទិញទំនិញ ឬ ទឹកប្រាក់ត្រលប់មកវិញ ដែលមានតម្លៃស្មើនឹងទឹកប្រាក់ 5ដុល្លារ នៅគ្រប់សាខាក្នុងរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្តរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ដែលមានប្រតិបត្តិការសេវាអ៊ីអនកាត។

# របៀបសន្សំពិន្ទុពី AEON Happy Plus Point




**លក្ខខណ្ឌ៖**

- រាល់ការចំណាយអស់ 2ដុល្លារ នឹងទទួលបាន 1ពិន្ទុ។ 500ពិន្ទុ អាចប្តូរជាប័ណ្ណទិញទំនិញ ដែលមានតម្លៃ 5ដុល្លារ ឬទឹកប្រាក់ត្រលប់មកវិញ។ មានតែម្ចាស់កាតដើមប៉ុណ្ណោះ ទើបអាចប្តូរពិន្ទុបាន។
- ការសន្សំពិន្ទុ នឹងត្រូវទទួលបានសម្រាប់រាល់ប្រតិបត្តិការទិញទំនិញតែប៉ុណ្ណោះ។ ការដកប្រាក់ជាមុន ថ្លៃសេវាប្រចាំឆ្នាំ ថ្លៃសេវាផ្សេងៗ និងការប្រាក់ នឹងមិនត្រូវបានគិតជាពិន្ទុទេ។
- AEON Happy Plus Point ដែលទទួលបានតាមរយៈកាតបន្ថែម នឹងត្រូវដាក់បញ្ចូលទៅក្នុងគណនី AEON Happy Plus Point របស់កាតដើម ដោយស្វ័យប្រវត្តិ។
- ពិន្ទុនឹងត្រូវអស់សុពលភាពក្នុងអំឡុងពេល 2ឆ្នាំ (ផុតកំណត់នៅថ្ងៃទី 31 ខែធ្នូ នៃឆ្នាំទី2) ។
- ការប្តូរពិន្ទុអាចធ្វើបាននៅគ្រប់សាខាក្នុងរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្តរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ដែលមានសេវាអ៊ីអនកាត។

**ការគ្រប់គ្រងពិន្ទុ ៖**

- លោកអ្នកអាចទាក់ទងទៅលេខ 070/078/023 988 555 ដើម្បីពិនិត្យមើលពិន្ទុរបស់លោកអ្នក ឬ ពិនិត្យលើរបាយការណ៍វិក្កយបត្រ ដើម្បីមើលព័ត៌មានលម្អិតអំពីពិន្ទុរបស់លោកអ្នក ឬ
- ទាញយកអ៊ីអនកាតម៉ូបាលនៅលើស្មាតហ្វូនរបស់អ្នក

GET IT ON Google Play
Download on the App Store
ÆON CARD MOBILE

ស្កេនទីនេះដើម្បីទាញយក

# កម្មវិធីផ្លាស់ប្តូរប្រភេទអ៊ីអនកាត

អ៊ីអនកាតពណ៌ស្វាយរបស់លោកអ្នក នឹងត្រូវផ្លាស់ប្តូរជាអ៊ីអនកាតពណ៌មាស ដោយលោកអ្នកគ្រាន់តែទិញទំនិញដោយប្រើប្រាស់អ៊ីអនកាតពណ៌ស្វាយរបស់លោកអ្នក អស់ចាប់ពី 3,000ដុល្លារឡើងទៅក្នុងមួយឆ្នាំតែប៉ុណ្ណោះ។




លក្ខខណ្ឌ៖

- ចំណាយអស់ចាប់ពី 3,000ដុល្លារឡើងទៅសម្រាប់ការទិញទំនិញក្នុងរយៈពេលពេញមួយឆ្នាំ ដោយប្រើប្រាស់អ៊ីអនកាតពណ៌ស្វាយរបស់លោកអ្នក ដោយមិនរាប់បញ្ចូលប្រតិបត្តិការដកសាច់ប្រាក់។
- ថ្លៃសេវាប្រចាំឆ្នាំ នឹងត្រូវបានលើកលែងសម្រាប់ឆ្នាំបន្ទាប់។
- ចំនួនប្រតិបត្តិការសរុប គឺត្រូវរាប់បញ្ចូលទាំងប្រតិបត្តិការដោយប្រើប្រាស់កាតបន្ថែម។
- មានប្រវត្តិទូទាត់សងល្អ
- ថ្លៃសេវាប្រចាំឆ្នាំនៃឆ្នាំបន្តបន្ទាប់ទៀត នឹងត្រូវបានលើកលែងចំពោះការប្រើប្រាស់កាតជាអប្បបរមាអស់ចំនួនទឹកប្រាក់ចាប់ពី 3,000ដុល្លារក្នុងមួយឆ្នាំ។
- ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី សូមរក្សាសិទ្ធិ និងជាឆន្ទានុសិទ្ធិដោយផ្តាច់មុខ និងដោយឯកតោភាគី ផ្លាស់ប្តូរប្រភេទអ៊ីអនកាតនេះ។

# ស្វែងយល់ពីអ៊ីអនកាតរបស់លោកអ្នក

## ផ្នែកខាងមុខនៃកាត

1. កាលបរិច្ឆេទផុតកំណត់
2. ឈ្មោះម្ចាស់កាត
3. លេខអ៊ីអនកាត
4. ការទទួលស្គាល់ទូទាំងពិភពលោក
5. សញ្ញា Visa payWave, Contactless Symbol

**1.** កាលបរិច្ឆេទ

សំដៅដល់កាលបរិច្ឆេទនៃខែ និងឆ្នាំ ដែលអ៊ីអនកាតរបស់លោកអ្នកត្រូវផុតកំណត់ ឬសុពលភាពប្រើប្រាស់




**2.** ឈ្មោះម្ចាស់កាត

**3.** លេខអ៊ីអនកាតរបស់លោកអ្នក

លេខនេះត្រូវការជាចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការ

**5.** សញ្ញា Visa payWave, Contactless Symbol

**4.** ការទទួលស្គាល់ទូទាំងពិភពលោក

## ផ្នែកខាងក្រោយនៃកាត

1. ព័ត៌មានសម្រាប់ទំនាក់ទំនង
2. ហត្ថលេខា
3. លេខ CVV2
4. បន្ទះម៉ាញ៉េទិច
5. ស្លាកសញ្ញា PLUS

**1.** ព័ត៌មានសម្រាប់ទំនាក់ទំនង

លោកអ្នកអាចប្រើប្រាស់ព័ត៌មាន លម្អិតនេះ ដើម្បីទាក់ទងទៅកាន់ផ្នែកបម្រើសេវាអតិថិជនរបស់យើងខ្ញុំ

**3.** លេខ CVV2

លេខនេះត្រូវប្រើប្រាស់នៅពេលអ្នកទិញទំនិញតាមទូរស័ព្ទ ឬតាមអនឡាញ

**4.** បន្ទះម៉ាញ៉េទិច




**2.** ហត្ថលេខា

ត្រូវមានហត្ថលេខារបស់លោកអ្នក ឬម្ចាស់កាតនៅទីនេះ

**5.** ស្លាកសញ្ញា PLUS

អាចដកសាច់ប្រាក់តាមម៉ាស៊ីន ATM ដែលមានស្លាកសញ្ញា PLUS

# តារាងតម្លៃសេវាកម្ម

| | | |
|---|---|---|
| កម្រៃសេវាប្រចាំឆ្នាំ | អ៊ីអនកាត ពណ៌ស្វាយ | មិនគិតថ្លៃ |
| | អ៊ីអនកាត ពណ៌មាស | 25 ដុល្លារ ក្នុងមួយឆ្នាំ |
| អត្រាការប្រាក់សម្រាប់ការទិញទំនិញ | អ៊ីអនកាត ពណ៌ស្វាយ | 28.8% ក្នុងមួយឆ្នាំ |
| | អ៊ីអនកាត ពណ៌មាស | 18.0% ក្នុងមួយឆ្នាំ |
| អត្រាការប្រាក់សម្រាប់ការដកសាច់ប្រាក់ជាមុន | អ៊ីអនកាត ពណ៌ស្វាយ | 28.8% ក្នុងមួយឆ្នាំ |
| | អ៊ីអនកាត ពណ៌មាស | 18.0% ក្នុងមួយឆ្នាំ |
| កម្រៃសេវាលើការដកសាច់ប្រាក់មុន | | 5 ដុល្លារ ឬក៏ 2% នៃចំនួនសាច់ប្រាក់ដែលបានដកជាមុន (យកចំនួនមួយណាដែលធំជាង) |
| កម្រៃសេវាចេញប័ណ្ណជំនួស | | 5 ដុល្លារ |
| កម្រៃសេវាចេញលេខកូដសម្ងាត់ថ្មី | | មិនគិតថ្លៃ |
| កម្រៃសេវាប្តូររូបិយប័ណ្ណបរទេសក្រៅពីដុល្លារ | | 2.0% |
| កម្រៃសេវាលើការប្រើប្រាស់លើសកម្រិតឥណទាន | | 10 ដុល្លារ |
| កម្រៃសេវាស្នើសុំពិនិត្យមើលវិក្កយបត្រលក់ | | 5 ដុល្លារ |
| ការគិតថ្លៃលើការទូទាត់សងយឺត | | ប្រសិនបើការទូទាត់សងចំថ្ងៃទី<br>6th - 10th : គិតថ្លៃ 1 ដុល្លារ<br>11th - 15th : គិតថ្លៃ 2ដុល្លារ<br>16th - 20th : គិតថ្លៃ 3ដុល្លារ |

# ផ្សេងៗ

| | |
|---|---|
| ការតម្កល់ប្រាក់ធានា | មិនតម្រូវ |
| ការទូទាត់សងអប្បបរមា | 10% នៃចំនួនទឹកប្រាក់ប្រតិបត្តិការសរុប និងការប្រាក់ បូករួមថ្លៃសេវាផ្សេងៗ ឬ 15ដុល្លារ (យកចំនួនមួយណាដែលធំជាង) |

# របាយការណ៍វិក្កយបត្រប្រចាំខែ



របាយការណ៍វិក្កយបត្រ
BILLING STATEMENT

ដើម្បីភាពងាយស្រួល សូមលោកអ្នកពិនិត្យរបាយការណ៍នេះ។ សូមអរគុណចំពោះការប្រើប្រាស់សេវាកម្មរបស់យើងខ្ញុំ។
Please check this statement for your convenience. Thank you for using our service.

កាលបរិច្ឆេទរបាយការណ៍ / STATEMENT DATE:

| | | |
|---|---|---|
| 1 លេខសម្គាល់អតិថិជន Customer Number | | |
| ប្រភេទប័ណ្ណ Card Type | | |
| 2 កាលបរិច្ឆេទកំណត់បង់ប្រាក់ Payment Due Date | | |
| ចំនួនទូទាត់ Payment Amount | ការទូទាត់អប្បបរមា Minimum Payment 3 | |
| | ការទូទាត់សរុប Full Payment | |
| វិធីសាស្ត្រនៃការទូទាត់ Payment Method | ☐ សាច់ប្រាក់ Cash | ☐ កាត់ស្វ័យប្រវត្តិ Auto Debit |
| គណនី Account | Bank | |
| | Branch | |
| | Name | |
| | Account No. | |

4

| ព័ត៌មានសង្ខេបអំពី HAPPY PLUS POINT / HAPPY PLUS POINT SUMMARY | |
|---|---|
| 5 ពិន្ទុពីមុន / Previous Points | ពិន្ទុ / Point |
| 6 ពិន្ទុដែលត្រូវបានទូទាត់ / Redeemed Points | ពិន្ទុ / Point |
| 7 ពិន្ទុសម្រាប់ខែនេះ / Points for this Month | ពិន្ទុ / Point |
| 8 ពិន្ទុសរុបចុងក្រោយ / Outstanding Points | ពិន្ទុ / Point |
| 9 ថ្ងៃដែលពិន្ទុផុតកំណត់ / Points Expiration | ពិន្ទុ/ Point |

| កម្រិតឥណទាន / CREDIT LIMIT | |
|---|---|
| កម្រិតឥណទានសរុប / Total Credit Limit | |
| ទិញទំនិញ / Purchase | |
| ដកសាច់ប្រាក់ / Cash Advance | |

សម្រាប់សំណួរ ឬព័ត៌មានបន្ថែម / FOR INQUIRY OR INFORMATION

| Call Center ( 8AM - 8PM ) | Website |
|---|---|
| 023 - 988 - 555 | www.aeon.com.kh |

សេចក្តីជូនដំណឹង /ANNOUNCEMENT

ប្រសិនបើលោកអ្នកមានអ៊ីអនកាតលើសពីមួយ ដូច្នេះកម្រិតឥណទានដែលបានកំណត់លើប័ណ្ណគឺជាឥណទានរួមនៃប័ណ្ណទាំងអស់
If you have more than one type of AEON Cards, the credit limit mentioned is total limit of all cards.

របាយការណ៍វិក្កយបត្រ / BILLING STATEMENT

| 10 កាលបរិច្ឆេទនៃប្រតិបត្តិការ Trans . Date (DD MM YY) | 11 អ្នកប្រើប្រាស់ User | 12 ការពិពណ៌នា Description | 13 ចំនួន ( ដុល្លារ ) Amount (USD) | សម្គាល់ Remarks |
|---|---|---|---|---|
| | | | | |

សម្គាល់ / Note: ❶ Pri ( អ្នកប្រើប្រាស់ប័ណ្ណចម្បង / Primary Cardholder ) ❷ Sup ( អ្នកប្រើប្រាស់ប័ណ្ណរង / Supplementary Cardholder )

សូមមេត្តាត្រួតពិនិត្យរបាយការណ៍របស់លោកអ្នកជាមួយបង្កាន់ដៃ។ ប្រសិនបើគ្មានការរាយការណ៍រយៈពេល 10ថ្ងៃនេះទេ របាយការណ៍លោកអ្នកនឹងត្រូវបានចាត់ទុកថាត្រឹមត្រូវ ហើយប្រសិនបើមានការជំទាស់ ឬមិនយល់ព្រម សូមមេត្តាទំនាក់ទំនងទៅកាន់ភ្នាក់ងារបម្រើសេវាកម្មរបស់អ៊ីអន។
Please examine the statement immediately upon receipt. If no error is reported within 10 days the statement will be considered correct. If you disagree, please contact officer at AEON Customer Service.

| សមតុល្យឥណទាន Credit Balance | ឥណទានទិញទំនិញ Credit Purchase | ដកសាច់ប្រាក់ Cash Advance | ថ្លៃសេវាកម្មផ្សេងៗ Other Fees | សរុប Total |
|---|---|---|---|---|
| សមតុល្យពីមុន / Previous Balance | | | | |
| ប្រតិបត្តិការថ្មី / New Transaction | | | | |
| សមតុល្យបច្ចុប្បន្ន / Current Balance | | | | |
| ការទូទាត់អប្បបរមា / Minimum Payment | | | | |
| ប្រាក់ដើម / Principal | | | | |
| ការប្រាក់ / Interest | | | | |
| ទឹកប្រាក់ត្រូវបង់អប្បបរមា / Minimum Payment Due | | | | |

ប្រតិបត្តិការដែលត្រូវបានបង្កើតនៅចន្លោះថ្ងៃទី11 និងថ្ងៃចេញរបាយការណ៍ គឺត្រូវបានរួមបញ្ចូលគ្នា / Transactions made between 11th and date of issue of this statement are included.

**AEON SPECIALIZED BANK (CAMBODIA) Public Limited Company**
6th floor (S603) of Diamond Twin Tower, Street Sopheak Monkul, Corner of Koh Pich, Sangkat Tonle Basak, Khan Chamkar Mon, Phnom Penh.

Page

1. លេខសម្គាល់អតិថិជន ៖ គឺជាលេខសម្គាល់របស់ម្ចាស់អ៊ីអនកាត (ត្រូវការប្រើលេខនេះ នៅពេលលោកអ្នកទូទាត់សងតាមរយៈភ្នាក់ងារ)
2. កាលបរិច្ឆេទដែលត្រូវបង់ប្រាក់ ៖ កាលបរិច្ឆេទដែលត្រូវទូទាត់សង (យ៉ាងហោចណាស់ចំនួនអប្បបរមា ដែលត្រូវទូទាត់សង) ដើម្បីជៀសវាងការពិន័យ។
3. ការទូទាត់អប្បបរមា ៖ ចំនួនអប្បបរមា ដែលលោកអ្នកត្រូវទូទាត់សង ចំនួន15ដុល្លារ ឬ10% នៃចំនួនទឹកប្រាក់ប្រតិបត្តិការសរុប (រួមបញ្ចូលទាំងការប្រាក់ និងថ្លៃសេវាផ្សេងៗទៀត)។
4. ព័ត៌មានសង្ខេបអំពី Happy Plus Point ៖ សេចក្តីសង្ខេបអំពីពិន្ទុសន្សំរបស់លោកអ្នក
5. ពិន្ទុពីមុន ៖ សេចក្តីសង្ខេបអំពីពិន្ទុសរុបនៃខែមុន
6. ពិន្ទុដែលត្រូវបានទូទាត់ ៖ ពិន្ទុដែលបានប្តូរកាលពីខែមុន
7. ពិន្ទុសម្រាប់ខែនេះ ៖ ពិន្ទុបូកសរុបខែនេះ
8. ពិន្ទុសរុបចុងក្រោយ ៖ ពិន្ទុសរុបដែលទទួលបាននៅក្នុងគណនីរបស់លោកអ្នក
9. ថ្ងៃដែលពិន្ទុផុតកំណត់ ៖ កាលបរិច្ឆេទដែលពិន្ទុផុតកំណត់
10. កាលបរិច្ឆេទប្រតិបត្តិការ ៖ កាលបរិច្ឆេទដែលប្រតិបត្តិការបានធ្វើឡើង
11. អ្នកប្រើប្រាស់ ៖ បុគ្គលដែលធ្វើប្រតិបត្តិការ
12. ការពិពណ៌នា ៖ ចំណុចនេះផ្តល់ព័ត៌មានលម្អិតអំពី ការទូទាត់សងទាំងអស់ ការទិញទំនិញ ការដកសាច់ប្រាក់ និងកម្រិតឥណទាន ដែលបានប្រើប្រាស់នៅក្នុងអំឡុងពេលចេញរបាយការណ៍។
13. ចំនួន (ដុល្លារ)៖ រាយចំនួនទឹកប្រាក់ប្រតិបត្តិការជាមួយការទូទាត់សងនីមួយៗ ការទិញទំនិញ ការដកសាច់ប្រាក់ ឬកម្រិតឥណទាន។ គ្រប់ប្រតិបត្តិការដែលមិនមែនជាដុល្លារ ត្រូវប្តូរទៅជាដុល្លារ។

# ការទូទាត់សងអ៊ីអនកាតរបស់លោកអ្នក




រីករាយជាមួយការមិនគិតការប្រាក់រហូតដល់ **52**ថ្ងៃ ដោយធ្វើការទូទាត់សរុបលើ ទឹកប្រាក់ទិញទំនិញនៃអ៊ីអនកាតរបស់លោកអ្នក។

កាលបរិច្ឆេទផ្ដាច់ចេញប្រចាំខែទៅលើប្រតិបត្តិការកាតរបស់លោកអ្នក គឺរៀងរាល់ ថ្ងៃទី **10** នៃខែនីមួយៗ ហើយធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី នឹង ផ្ញើរបាយការណ៍វិក្កយបត្រនៅត្រឹមថ្ងៃទី **27** នៃខែនីមួយៗ ហើយកាលបរិច្ឆេទ កំណត់ទូទាត់សង គឺនៅរៀងរាល់ថ្ងៃទី **2** នៃខែបន្ទាប់។

លោកអ្នកអាចជ្រើសរើស **(1)** ទូទាត់សងសរុប **(2)** ទូទាត់សងអប្បបរមា ឬ **(3)** ចំនួន ណាមួយ ដែលធំជាងចំនួនអប្បបរមា ដោយត្រូវបង់ទូទាត់សងនៅពេលណាមួយត្រឹម ឬមុនកាលបរិច្ឆេទផុតកំណត់ទូទាត់សង ។

ប្រសិនបើលោកអ្នកជ្រើសរើសទូទាត់តិចជាងចំនួន ដែលត្រូវទូទាត់សងសរុប ចំនួន ដែលនៅសល់នឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍បន្ទាប់ដោយត្រូវគិតការប្រាក់។

**ឧទាហរណ៍៖ ប្រតិបត្តិការនៅក្នុង ខែកញ្ញា និង ខែតុលា**



# តើលោកអ្នកទូទាត់របាយការណ៍វិក្កយបត្រយ៉ាងដូចម្តេច?

## វិធីសាស្ត្រនៃការទូទាត់សង

### 1. ប្រភេទនៃការទូទាត់

| | |
|---|---|
| ការទូទាត់សងសរុប | ទូទាត់សងទឹកប្រាក់ទាំងអស់ នៃសមតុល្យដែលត្រូវសងសរុប |
| ការទូទាត់សងអប្បបរមា | 10% នៃចំនួនប្រតិបត្តិការ និងការប្រាក់បូក ជាមួយថ្លៃសេវាផ្សេងៗ ឬ 15ដុល្លារ(យកចំនួនណាមួយដែលធំជាង)។ |

### 2. របៀបធ្វើការទូទាត់

| | |
|---|---|
| ការទូទាត់ដោយស្វ័យប្រវត្តិ | លោកអ្នកអាចធ្វើឥណពន្ធដោយស្វ័យប្រវត្តិនូវទឹកប្រាក់អប្បបរមា ឬទឹកប្រាក់សរុបចេញពីគណនីធនាគាររបស់លោកអ្នក ដែល ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី សហការជាមួយ។ កម្រៃសេវាកម្ម គឺមិនតម្រូវឲ្យបង់សម្រាប់ការទូទាត់សងតាមឥណពន្ធដោយស្វ័យប្រវត្តិ។ |
| ការទូទាត់សងតាមរយៈភ្នាក់ងារ | លោកអ្នកអាចទូទាត់ចំនួនណាមួយនៅក្នុងសមតុល្យសរុបរបស់លោកអ្នកតាមរយៈធនាគារ ដែលជាដៃគូសហការ ឬភ្នាក់ងាររបស់យើងខ្ញុំ។ |

## ភ្នាក់ងារទូទាត់

| ភ្នាក់ងារទូទាត់ | របៀបនៃការទូទាត់ | | | |
|---|---|---|---|---|
| | ការកាត់ស្វ័យប្រវត្តិ | ការទូទាត់តាមបញ្ជរបង់ប្រាក់ | ការទូទាត់តាមរយៈកម្មវិធីទូរស័ព្ទ | លេខគណនី |
| អេស៊ីលីដា ACLEDA<br>ធនាគារ អេស៊ីលីដា<br>គ្រប់សាខាទាំងអស់ទូទាំងប្រទេស | មិនគិតប្រាក់ | 0.50 ដុល្លារ | 0.25 ដុល្លារ | 0001-01-410992-1-2<br>ACLEDA Unity Toanchet<br>ជ្រើសយក "Loan Repayment" |
| Wing<br>ភ្នាក់ងារ វីង ទាំងអស់ទូទាំងប្រទេស | មិនគិតប្រាក់ | 0.50 ដុល្លារ | 0.50 ដុល្លារ | 1366 |
| Maybank<br>ធនាគារ មេយប៊ែង<br>គ្រប់សាខាទាំងអស់ទូទាំងប្រទេស | មិនគិតប្រាក់ | 0.50 ដុល្លារ | មិនគិតប្រាក់ | 00001-02-002177-01 |
| ធនាគារ ចិន សាខាភ្នំពេញ | មិនមាន | 0.30 ដុល្លារ | មិនមាន | 100001100154027 |
| ធនាគារ កម្ពុជាសាធារណៈ<br>គ្រប់សាខាទាំងអស់ទូទាំងប្រទេស | មិនមាន | 0.30 ដុល្លារ | មិនមាន | 010-02-13-06666-7 |
| CIMB BANK<br>ធនាគារ ស៊ីអាយអិមប៊ី<br>គ្រប់សាខាទាំងអស់ទូទាំងប្រទេស | មិនមាន | 0.50 ដុល្លារ | មិនមាន | 101012300000582 |
| truemoney<br>ភ្នាក់ងារ ទ្រូម៉ាន់នី | មិនគិតប្រាក់ | 0.50 ដុល្លារ<br>ចំនួនចាប់ពី 1ដុល្លារ ដល់ 2,500 ដុល្លារ<br>1 ដុល្លារ<br>ចំនួនចាប់ពី 2,500.01 ដុល្លារ ដល់ 10,000 ដុល្លារ | 0.50 ដុល្លារ<br>ចំនួនចាប់ពី 1ដុល្លារ ដល់ 2,500 ដុល្លារ<br>1 ដុល្លារ<br>ចំនួនចាប់ពី 2,500.01 ដុល្លារ ដល់ 10,000 ដុល្លារ | 1366 |













# ការការពារពីការក្លែងបន្លំអ៊ីអនកាត

## 1. រក្សាអ៊ីអនកាតរបស់លោកអ្នកឲ្យមានសុវត្ថិភាព

- ចុះហត្ថលេខាលើបន្ទះហត្ថលេខានៃកាតរបស់លោកអ្នកភ្លាមៗ នៅពេលដែលលោកអ្នកទទួលបានកាត។
- រក្សាទុកកាតរបស់លោកអ្នកនៅកន្លែងមានសុវត្ថិភាព និងចាត់ទុកវាដូចជាសាច់ប្រាក់។
- កុំភ្លេចដកយកកាតរបស់លោកអ្នកពីម៉ាស៊ីន ATM បន្ទាប់ពីប្រើប្រាស់រួច។
- រក្សាទុកនូវច្បាប់ថតចម្លងនៃវិក្កយបត្រលក់ និងផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍វិក្កយបត្ររបស់លោកអ្នក។
- ត្រូវប្រាកដថា កាតរបស់លោកអ្នកត្រូវបានប្រគល់ឲ្យលោកអ្នកវិញ។
- ទាក់ទងទៅផ្នែកបម្រើសេវាអតិថិជនរបស់យើងខ្ញុំ សម្រាប់ព័ត៌មានបន្ថែមតាមរយៈលេខទូរស័ព្ទ 070/078/023 988 555 ។

## 2. សុវត្ថិភាពនៃលេខកូដសម្ងាត់

- មិនត្រូវរក្សាទុកកំណត់ត្រាអំពីលេខកូដសម្ងាត់របស់លោកអ្នក (PIN) ឡើយ។ ជំនួសមកវិញ គឺត្រូវចងចាំវា។
- មិនត្រូវអនុញ្ញាតឲ្យនរណាម្នាក់ប្រើប្រាស់កាតរបស់លោកអ្នក និងមិនត្រូវបង្ហាញលេខកូដសម្ងាត់ទៅកាន់នរណាឡើយ។
- ត្រូវប្រាកដថាលេខកូដសម្ងាត់ មិនត្រូវបានគេមើលឃើញនៅពេលដែលលោកអ្នកប្រើប្រាស់នៅម៉ាស៊ីន ATM ឬតាមម៉ាស៊ីនទូទាត់ឡើយ។
- ប្រសិនបើលោកអ្នកគិតថានរណាម្នាក់បានឃើញ ឬដឹងលេខកូដសម្ងាត់របស់លោកអ្នក ត្រូវប្តូរចេញភ្លាម។

## 3. បាត់ ឬចោរលួច

- ប្រសិនបើកាតរបស់លោកអ្នកបានបាត់ ឬត្រូវចោរលួច ឬប្រសិនបើលេខកូដសម្ងាត់ត្រូវបានដឹងដោយតតិយជនណាមួយ  សូមរាយការណ៍អំពីឧប្បត្តិហេតុនោះភ្លាមៗ ដោយទាក់ទងទៅផ្នែកបម្រើសេវាអតិថិជនរបស់យើងខ្ញុំតាមរយៈលេខទូរស័ព្ទ 023 988 655 ។
- រហូតទាល់តែ ឬលុះត្រាតែមានការជូនដំណឹងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរអំពីការបាត់ ឬត្រូវចោរលួចកាតពីម្ចាស់កាត ត្រូវបានទទួលដោយ ធនាគារឯកទេស អ៊ីអន ( ខេមបូឌា ) ភីអិលស៊ី ម្ចាស់កាតត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការទាំងអស់ ដែលកើតឡើងមុនការជូនដំណឹង ទោះបីជាការប្រើប្រាស់កាតត្រូវបាន ឬមិនត្រូវបានអនុញ្ញាតដោយម្ចាស់កាតក៏ដោយ។
- ប្រសិនបើកាត ឬ/និងលេខកូដសម្ងាត់ ដែលបានរាយការណ៍ថាបានបាត់ ឬត្រូវចោរលួច រកឃើញវិញក៏ដោយ ក៏មិនត្រូវប្រើកាតនោះទៀតឡើយ។

# ដំណើរការនៃការចេញកាត និងលេខកូដសម្ងាត់ថ្មី




- ការចេញកាត និង/ឬ លេខកូដសម្ងាត់ថ្មី មាននៅគ្រប់សាខាក្នុងរាជធានីភ្នំពេញ និង សាខាតាមបណ្តាខេត្តរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ដែលមានប្រតិបត្តិការសេវាអ៊ីអនកាត ។
- ម្ចាស់កាតត្រូវបំពេញពាក្យស្នើសុំសម្រាប់អតិថិជន ។
- សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកផ្នែកបម្រើសេវាអតិថិជនតាមរយៈលេខទូរស័ព្ទ 070/078/023 988 555 ។



ÆON
ធនាគារឯកទេស